**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ២៦៣៧/២២ មស. សរណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៥
## ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការថ្នាក់ជាតិ នៃក្រសួងមុខងារសាធារណៈ

យោងសេចក្តីជូនព័ត៌មានលេខ៧០៤/២២ គ.រ.ក-១៩ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ស្តីពី យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៥ ជូនដល់មន្ត្រីជួរមុខ និងក្រុមគោលដៅអាទិភាព នោះ តំណាងឱ្យអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងមុខងារសាធារណៈ ខ្ញុំសូមគោរពជម្រាបជូនដំណឹងដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា** ថ្នាក់ជាតិរបស់ក្រសួងដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៤ រួច ហើយមានគន្លាតយ៉ាងតិច ៣ខែឡើង បន្ទាប់ពីដូសទី៤ មេត្តាជ្រាបថា ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៥ នឹងប្រព្រឹត្តទៅ**ចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង១១:០០នាទីព្រឹក និងចាប់ពីម៉ោង១៤:០០នាទី ដល់ម៉ោង១៧:០០នាទី** ទៅតាមថ្ងៃខែឆ្នាំ និងទីកន្លែងកំណត់ដូចខាងក្រោម៖

**១. ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២**

- **មន្ទីរពេទ្យកាល់ម៉ែត** សម្រាប់ចាក់ជូនឥស្សរជនដែលមានតួនាទីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ
- **មន្ទីរពេទ្យព្រះអង្គឌួង** សម្រាប់ចាក់ជូនឥស្សរជនដែលមានតួនាទីជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ

**២. ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២**

- **មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក** សម្រាប់ចាក់ជូនមន្ត្រីរាជការដែលមានតួនាទីចាប់ពី ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា

ឯកសារដែលត្រូវយកទៅជាមួយមានដូចខាងក្រោម៖

- ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យា
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារប្រើប្រាស់ក្នុងការចុះឈ្មោះកាលពីចាក់វ៉ាក់សាំងដូសទី១

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៥ ដូចបានកំណត់ខាងលើឱ្យបានគ្រប់គ្នា។

ថ្ងៃអង្គារ ៨ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២
**រដ្ឋលេខាធិការ**
**ប្រធានអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩**
**របស់ក្រសួងមុខងារសាធារណៈ**

**អេង ប៊ុនថុល**